**ព្រះរាជាណាចក្រ កម្ពុជា**
*Kingdom Of Cambodia*

**ជាតិ សាសនា ព្រះមហាក្សត្រ**
Nation Religion King

**គណៈកម្មការវាយតំលៃដីមិនបានប្រើប្រាស់**
Land Appraisal and Valuation Committee

លេខ : ០០៧ ....សសរ.សហវ.ពដ

រាជធានីភ្នំពេញ,ថ្ងៃទី ៧០ ខែ ១ ឧសភា ឆ្នាំ២០០២

# សេចក្តីសំរេច

## ស្តីពី

## ការកែប្រែសមាសភាពអនុគណៈកម្មការវាយតម្លៃដីមិនបានប្រើប្រាស់

## នៅខេត្ត រតនគិរី

~~~~~~~

## ប្រធានគណៈកម្មការវាយតម្លៃដីមិនបានប្រើប្រាស់

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស-រកត-១១៩៨-៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២-នស-៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស-រកម-០១៩៦-១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ១១-នស-៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ១៩៩៤
- បានឃើញច្បាប់ស្តីពីសារពើពន្ធដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស-រកម-០២៩៧-០៣ ចុះថ្ងៃទី ២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧
- បានឃើញអនុក្រឹត្យលេខ ៥៨-អនក្រ-ចុះថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតគណៈកម្មការវាយតម្លៃដីមិនបានប្រើប្រាស់
- បានឃើញប្រកាសលេខ ៧២៤ ប្រក.សហវ.ពដ ចុះថ្ងៃទី ០៥ ខែកក្កដា ឆ្នាំ១៩៩៦ ស្តីពីការប្រមូលពន្ធលើដីធ្លីមិនបានប្រើប្រាស់
~~~~~~~

- បានឃើញប្រកាសលេខ ៧៨៤-ប្រក-សហវ-ពជ ចុះថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ១៩៩៦ ស្តីពីការកំណត់មេគុណសម្រាប់អនុវត្តក្នុងការប្រមូលពន្ធលើដីធ្លីមិនបានប្រើប្រាស់
- បានឃើញសេចក្តីសំរេចលេខ ០០៤-សសរ-សហវ-ពជ ចុះថ្ងៃទី ២៤ ខែ សីហា ឆ្នាំ១៩៩៧ ស្តីពីការប្រមូលពន្ធលើដីធ្លីមិនបានប្រើប្រាស់
- បានឃើញប្រកាសលេខ ៣៩៣ ប្រក.សហវ.ពជ ចុះថ្ងៃទី១៧ ខែ ឧសភា ឆ្នាំ១៩៩៩ ស្តីពីការកែប្រែសមាសភាពគណៈកម្មការវាយតម្លៃដីធ្លីមិនបានប្រើប្រាស់
- បានឃើញសេចក្តីសំរេចលេខ ០០២ សសរ.ពជ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ២០០០ ស្តីពីការបង្កើតអនុគណៈកម្មការវាយតម្លៃដីមិនបានប្រើប្រាស់នៅខេត្តរតនគិរី ខេត្តព្រះវិហារ និង ក្រុងប៉ៃលិន
- យោងតាមដីការលេខ ៤០៨/០២ ចុះថ្ងៃទី ០២ ខែមេសា ឆ្នាំ២០០២ របស់សាលាខេត្តរតនគិរី ស្តីពីការបង្កើតអនុគណៈកម្មការវាយតម្លៃដីមិនបានប្រើប្រាស់ ។
- យោងតាមការងារចាំបាច់ក្នុងការប្រមូលពន្ធលើដីធ្លីមិនបានប្រើប្រាស់នៅខេត្តរតនគិរី ។

## សំរេច

**ប្រការ១** : សមាសភាពនៃអនុគណៈកម្មការវាយតម្លៃដីមិនបានប្រើប្រាស់នៅខេត្តរតនគិរី ដែលមានចែងនៅក្នុងប្រការ១ លេខរៀងទី១នៃសេចក្តីសំរេចលេខ ០០២ សសរ.ពជ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០០០ ស្តីពីការបង្កើតអនុគណៈកម្មការវាយតម្លៃដីមិនបានប្រើប្រាស់ខេត្តរតនគិរី ខេត្តព្រះវិហារ និង ក្រុងប៉ៃលិន ត្រូវបានធ្វើការកែប្រែដូចតទៅ :

| | | |
|---|---|---|
| ១- ឯកឧត្តម **មួង ម៉យ** | អភិបាលរងទី២ខេត្ត | ជាប្រធាន |
| ២- លោក **ខាំ សែ** | ប្រធានមន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ខេត្ត | ជាអនុប្រធាន |
| ៣- លោក **ថៅ នុច** | ប្រធានសាខាពន្ធដារខេត្ត | ជាសមាជិកអចិន្ត្រៃយ៍ |
| ៤- លោក **ឆឹម សុិណាត** | ប្រធានមន្ទីររៀបចំដែនដីនគរូបនីយកម្ម សំណង់ និង សុរិយោដីខេត្ត | ជាសមាជិកអចិន្ត្រៃយ៍ |
| ៥- លោក **ឆាយ ទុិត** | ប្រធានមន្ទីរកសិកម្មរុក្ខាប្រម៉ាញ់និងនេសាទខេត្ត | ជាសមាជិក |
| ៦- លោក **ក្ហុយ ជៀចធុីនសែ** | នាយក្រុមហិរញ្ញវត្ថុសាលាខេត្ត | ជាសមាជិក |
| ៧- លោក **អភិបាលស្រុកគ្រប់ស្រុកក្នុងខេត្ត** | | ជាសមាជិក |

**ប្រការ២** : អនុគណៈកម្មការមានភារកិច្ច :

- ផ្សព្វផ្សាយជាសាធារណៈនូវច្បាប់ស្តីពីការប្រមូលពន្ធលើដីធ្លីមិនបានប្រើប្រាស់
- បង្កើតបញ្ជីដីត្រូវជាប់ពន្ធ តាមតំបន់ក្នុងខេត្ត-ក្រុង
- លើកតំរោងតម្លៃដីក្នុងមួយម៉ែត្រក្រឡា គិតតាមតំបន់នីមួយៗក្នុងខេត្ត-ក្រុង ដើម្បីជាមូលដ្ឋានគណនាប្រាក់ពន្ធដាក់ជូនគណៈកម្មការវាយតម្លៃដីមិនបានប្រើប្រាស់ពិនិត្យនិងសំរេច
- ផ្តល់មតិចំពោះរឿងវិវាទនានា ដែលពាក់ព័ន្ធទៅនឹងដីមិនបានប្រើប្រាស់ ។

**ប្រការ៣** : អនុគណៈកម្មការអាចរៀបចំបង្កើតក្រុមជំនួយការមួយ ដើម្បីធានានិរន្តភាពក្នុងប្រតិបត្តិការរបស់អនុគណៈកម្មការ។

**ប្រការ៤ :** សមាជិកអនុគណៈកម្មការត្រូវចូលរួមធ្វើការងារ និង ប្រជុំតាមសេចក្ដីអញ្ជើញរបស់ប្រធានអនុគណៈកម្មការ ។

**ប្រការ៥ :** អនុគណៈកម្មការត្រូវចូលរួមធ្វើការងារ និង ប្រជុំតាមសេចក្ដីអញ្ជើញរបស់ប្រធានគណៈកម្មការ និង ត្រូវរាយការណ៍ជាប្រចាំតាមខែនីមួយៗ មកគណៈកម្មការវាយតម្លៃដីមិនបានប្រើប្រាស់នៅក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

**ប្រការ៦ :** ឯកឧត្តម អស់លោក ដូចមានរាយនាមក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្ដីសំរេចនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**<u>កន្លែងទទួល</u> :**

- ខុទ្ទកាល័យព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- សាលាខេត្តរតនគិរី "ដើម្បីជូនជ្រាបជាពត៌មាន"
- ដូចប្រការ៦ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

**ប្រធានគណៈកម្មការវាយតម្លៃដីមិនបានប្រើប្រាស់**

**[illegible] វិបុល**

**រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**